# ដំណាំត្រសក់ស្រូវ



## ការរៀបចំដីដាំ

- រៀបចំរងទំហំ១ម៉ែត្រ (ត្រូវមានកំពស់ ៣០ ស.ម យ៉ាងតិចនៅរដូវវស្សា)
- ពង្រាយដីលាមកគោស្ងួតរឺដីកំប៉ុស្ត៍ និងដីកែងៗ ពេញរងហើយកាប់ប្រចល់ជាមួយដីអោយសព្វល្អ
- គ្របរងដោយ ចំបើអោយបានកំរាស់យ៉ាងតិច៥ សង់ទីម៉ែត្រ រឺប្រើគំរបដីផ្លាស់ស្ទិកដើម្បីការពារស្មៅចង្រៃ និងរក្សាសំណើមដី



ការបណ្តុះកូន: ដើម្បីឲ្យបានកូនត្រប់ដែលមានសុខភាពល្អ យើងត្រូវបណ្តុះកូនតាមរបៀបខាងក្រោម:

- រៀបចំកន្ទោងបណ្តុះ (ស្លឹកត្នោត រឺស្លឹកចេក) ឬ ថាសបណ្តុះ
- យកដីមានជីជាតិ(ដីដំបូក)១ភាគ ដីកំប៉ុស្ត៍រឺដីលាមកគោដែលរលួយ១ភាគ និងផេះអង្កាម១ភាគ លាយជាមួយគ្នាហើយយកទៅ លីងអោយក្តៅបំផុត រួចទុកអោយត្រជាក់ទើបដាក់កន្ទោង។ បើមិនលីងល្បាយដីទេ កូនដំណាំងាយមានជំងឺផ្សិតធ្វើឱ្យលួយបាន។
- បណ្តុះតែ១គ្រាប់ក្នុងមួយកន្ទោង ដាក់គ្រាប់ផ្តេក នៅពេលបណ្តុះ ត្រូវគ្របសំណាញ់សត្វល្អិត និងធ្វើដំបូលគ្របអំពីស្លឹកដូង រឺ សំណាញ់កាត់ពន្លឺនៅរដូវក្តៅ និងរដូវវស្សាត្រូវធ្វើដំបូលការពារទឹកភ្លៀង ពីព្រោះកូនដំណាំនៅតូចមិនត្រូវការពន្លឺ និងទឹកច្រើនទេ។



- ស្រោចទឹក១ថ្ងៃមួយដងនៅពេលព្រឹក (បើទុកដីបណ្តុះស្ងួត គ្រាប់មិនអាចដុះបានទេ បើកូនដុះហើយក៏នៅក្រិនដែរ)

កូនដំណាំមានសុខភាពល្អ ជួយអោយដំណាំធំលឿន កាត់បន្ថយការបំផ្លាញពីជំងឺ សត្វល្អិត និងទទួលទិន្នផលបានស្មើគ្នា

## ការដាំកូនត្រសក់

- ត្រូវដាក់កូនត្រសក់ឲ្យត្រូវចំពន្លឺថ្ងៃចំនួន២ ឬ៣ថ្ងៃ មុនដាំ ដើម្បីឲ្យដើមរឹងមាំល្អហើយផ្សាំនិងអាកាសធាតុនៅខាងក្រៅ
- កូនត្រសក់អាយុបាន៥-៧ថ្ងៃ អាចយកដាំបាន(អាស្រ័យតាមការថែទាំកូន)
- ស្រោចទឹកកូនត្រសក់ឲ្យសើមល្មមនៅពេលព្រឹកទើបយកូនត្រសក់ទៅដាំនៅពេលរសៀល
- យកកូនចេញពីកន្ទោង ឬថាសបណ្តុះដោយប្រុងប្រយ័ត្នបំផុតមិនត្រូវឲ្យដាច់ ឬសកូនត្រសក់ឡើយ ព្រោះធ្វើអោយកូនត្រសក់អន់បាននៅពេលដាំ



- ត្រូវស្រោចទឹកកូនត្រសក់អោយបានគ្រប់គ្រាន់បន្ទាប់ពីដាំហើយ ជាពិសេសរវាងពី២-៣ អាទិត្យបន្ទាប់ពីដាំកូនហើយ

## ការថែទាំ

- ត្រូវស្រោចទឹកឲ្យបានគ្រប់គ្រាន់នៅពេលព្រឹកជៀសវាងស្រោចទឹកច្រើនពេកធ្វើអោយដីសើមជ្រុលនៅពេលថ្ងៃល្ងាច វាអាចបង្កឲ្យមានបញ្ហាដល់ដំណាំបាន
- ត្រូវដោតទ្រើងភ្លាមបន្ទាប់ពីដាំកូនហើយ តែអាចយឺតបំផុតចំនួន៧ថ្ងៃបន្ទាប់ពីដាំកូន ។ បើទុកឲ្យវាធំទើបដោតទ្រើងធ្វើអោយ ដាច់ឬសដំណាំ លូតលាស់យឺត ហើយងាយថយទិន្នផល
- ត្រូវកាត់ស្លឹកដែលនៅផ្នែកខាងក្រោមក្បែរដីចំនួន១ឬ២សន្លឹកចេញនៅរដូវវស្សា។



## ការប្រើប្រាស់ជី ( បើដាក់ជីត្រូវស្រោចទឹក ទើបដំណាំអាចចាប់យកជីបាន )

| ពេលវេលា | ប្រភេទជីប្រើ | កន្លែងដែលត្រូវដាក់ជី |
|---|---|---|
| ដាក់ជីទ្រាប់បាត | ជី អិន ប៉េ កា (១៥. ១៥.១៥)៧.៥ក្រាម (១ស្លាបព្រាបាយស្មើ)/ដើម លាមកសត្វ ០.៥ គីឡូក្រាម/ដើម | ពង្រាយលើរងហើយកាប់ច្របល់និងដី |
| ការដាំកូន | តែមួយដើម ក្នុងមួយរណ្តៅ | |
| ២ អាទិត្យបន្ទាប់ពីដាំ | ជីអ៊ុយរ៉េ ១០ក្រាម (១ចុងស្លាបព្រាបាយកំពុង)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់កន្លះតឹក |
| ៤ អាទិត្យបន្ទាប់ពីដាំ | ជី អិន ប៉េ កា (១៥. ១៥.១៥)២.៥ក្រាម (១ស្លាបព្រាបាយកំពុង)/ដើម ជីអ៊ុយរ៉េ ២.៥ក្រាម (១ចុងស្លាបព្រាបាយកំពុង)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់១តឹក |
| ៥ អាទិត្យបន្ទាប់ពីដាំ | ជីប៉ូតាស្យូម ១.៩ក្រាម (១ចុងស្លាបព្រាបាយស្មើ )/ដើម | កប់ជីរាក់ៗ ចំងាយពីគល់ ១តឹកកន្លះ |
| ៦ អាទិត្យបន្ទាប់ពីដាំ | ជី អិន ប៉េ កា (១៥. ១៥.១៥) ២.៥ ក្រាម (១ចុងស្លាបព្រាបាយកំពុង)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់ ១តឹកកន្លះ |
| ៨ អាទិត្យបន្ទាប់ពីដាំ | ជី អិន ប៉េ កា (១៥. ១៥.១៥) ២.៥ ក្រាម (១ចុងស្លាបព្រាបាយកំពុង)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់ ១តឹកកន្លះ |

## ការការពារសត្វល្អិត

- កុំដាំត្រសក់លើដីដដែលៗនាំកើតមានជំងឺ និងសត្វល្អិតកាន់តែច្រើន ជាហេតុពិបាកកំចាត់វា
- ឧស្សាហ៍ពិនិត្យមើលនៅតាមត្រួយត្រសក់ ពិសេសនៅរដូវក្តៅ ដែលសំបូរដោយពពួកទ្រីបជញ្ជក់ត្រួយត្រសក់ហើយជាអ្នកចំលងជំងឺវីរុសដល់ត្រសក់នោះមិនអាចព្យាបាលបាន ។

## ជំងឺលឿងស្លឹក:

ស្លឹកត្រសក់ចាប់ផ្តើមមានចំនុចអុចៗពណ៌លឿង ហើយប្រែជាពណ៌ត្នោត ។ វាកើតពីស្លឹកនៅក្បែរដីរាលទៅស្លឹកផ្នែកខាងលើ ។

- ត្រូវបាញ់ថ្នាំផ្សិត៥ថ្ងៃម្តងនៅរដូវភ្លៀង និង៧ថ្ងៃម្តងនៅរដូវប្រាំងតាំងពីកូនត្រសក់ដុះបានស្លឹក២ដើម្បីការពារជាមុន ។
- បើត្រសក់មានជំងឺផ្សិតហើយ យើងត្រូវកាត់ស្លឹកទាំងនេះចេញសិនមុន និងបាញ់ថ្នាំផ្សិត ។ ស្លឹកនេះត្រូវយកទៅកប់ចោល រឺធ្វើជាជីកុំប៉ុស្តបាន ។កុំទុកស្លឹកនេះនៅក្នុងចំការ វាធ្វើឲ្យឆ្លងទៅដើមផ្សេងទៀត ។
- សូមបាញ់ថ្នាំផ្សិតនៅពេលម៉ោង៤ទៅម៉ោង៥ល្ងាច ។ ដោយសារផ្សិតជំងឺនៅខាងក្រោមស្លឹក ដូចនេះយើងត្រូវបាញ់ថ្នាំ នៅផ្នែកខាងក្រោមស្លឹកឆ្ពោះទៅខាងលើ ។ កុំបាញ់នៅពេលមេឃជិតធ្លាក់ភ្លៀង មានខ្យល់ និងនៅពេលថ្ងៃត្រង់ ។

## ប្រការចងចាំ

- កុំប្រើថ្នាំឈ្មោះកំចាត់សត្វល្អិតនិងជំងឺដដែលៗ វាធ្វើអោយសត្វល្អិតនិងជំងឺមានភាពធន់ទ្រាំជាមួយថ្នាំ ពិបាកកំចាត់នៅពេលក្រោយ ។
- កុំប្រើថ្នាំពុលលាយចូលគ្នានៅពេលបាញ់ វាធ្វើឲ្យថ្នាំគ្មានប្រសិទ្ធិភាព ហើយសត្វល្អិត ដង្កូវរហ័សសាំ និងថ្នាំ ពិបាកកំចាត់វាពេលក្រោយ ។

## ការប្រមូលផល

បេះផ្លែត្រសក់នៅពេលព្រឹក និងមិនត្រូវទុកផ្លែដែលបេះហើយអោយត្រូវថ្ងៃក្តៅទេ ៕

ឯកសារពិគ្រោះ
- សៀវភៅណែនាំអំពីបច្ចេកទេសដំណាំបន្លែ, ២០១១
- សៀវភៅណែនាំបច្ចេកទេសកសិករ ផលិតកម្មដំណាំបន្លែ, ២០១៣

សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្មតាមសយដ្ឋានខាងក្រោម:
លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣)-២១៥ ៨១៩/០១២ ៨២៦ ៦១៧

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ដំណាំសណ្តែកកួរ



សហការផលិតដោយ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់-ក្រចាក់បៃតង ខេត្តសៀមរាប
២០១៣